1-877-328-9677

តើត្រូវប្រើប័ណ្ណ EBT របស់លោកអ្នកដើម្បីទិញម្ហូបចំណីក្នុងបែបណា?

មុនពេលលោកអ្នកអញ្ជើញទៅហាងលក់ទំនិញ សូមឆែកមើលចំនួនប្រាក់នៅសល់ក្រោយពីការទូទាត់របស់លោកអ្នក ដែលបង្ហាញនៅពីលើបង្គាន់ដៃចុងក្រោយរបស់លោកអ្នក ឬទូរស័ព្ទទៅផ្នែកបំរើអតិថិជន តាមលេខគត់គិតថ្លៃ 1-877-328-9677 ចំនួនប្រាក់នៅសល់ក្រោយពីការទូទាត់នេះ គឺជាចំនួនប្រាក់ច្រើនបំផុតមាននៅក្នុងប័ណ្ណ ដែលលោកអ្នកអាចចាយបាន ។

ជំហានទី 1 យកគ្រឿងធ្វើម្ហូបរបស់លោកអ្នកទៅកាន់តន្លែងបង់ប្រាក់ ។ ដោយពិងផ្អែកទៅលើហាងលក់ទំនិញ លោកអ្នកប្រហែលជាត្រូវដាក់មុខម្ហូបចំណីដែលលោកអ្នកមានសិទ្ធិទិញ ដាច់ដោយឡែកពីមុខរបស់ដែលលោកអ្នកមិនអាចមានសិទ្ធិទិញបាន ។

ជំហានទី 2 ឆូតប័ណ្ណរបស់លោកអ្នកក្នុងម៉ាស៊ីននៅចំណុចលក់ទំនិញ (POS) ឬ ហុចប័ណ្ណ EBT របស់លោកអ្នកទៅអោយបុគ្គលិកហាងលក់ទំនិញ ។

ជំហានទី 3 ដាក់បញ្ចូលលេខសម្ងាត់ PIN បួនខ្ទង់របស់លោកអ្នកពីលើផ្ទាំងបន្ទះសំរាប់ចុច ។ ម៉ាស៊ីនគឺងបង្ហាញជាសញ្ញា **** ជំនួសលេខដែលលោកអ្នកបានដាក់បញ្ចូលនោះ ។

ជំហានទី 4 សូមចុចពាក្យ [Enter] ។

ជំហានទី 5 បុគ្គលិកហាងលក់ទំនិញដាក់បញ្ចូលចំនួនប្រាក់ដែលលោកអ្នកទិញ ។ ប្រសិនបើចំនួនប្រាក់នោះត្រឹមត្រូវ លោកអ្នកត្រូវចុចពាក្យ [OK] ឬពាក្យ [YES] ។

ជំហានទី 6 លោកអ្នកនឹងបានទទួលសំណៅបង្គាន់ដៃបោះពុម្ពមួយច្បាប់ ដែលបង្ហាញប្រាប់អំពី:

- ឈ្មោះហាងលក់ទំនិញ និងអាស័យដ្ឋាន
- ចំនួនប្រាក់ដែលលោកអ្នកទិញ
- ចំនួនប្រាក់នៅសល់ថ្មីក្រោយពីការទូទាត់ ដែលមាននៅក្នុងប័ណ្ណទិញម្ហូបចំណីរបស់លោកអ្នក

ជំហានទី 7 សូមរក្សាទុកបង្គាន់ដៃរបស់លោកអ្នកដើម្បីអោយលោកអ្នកបានដឹងអំពីចំនួនប្រាក់នៅសល់ថ្មី ក្រោយពីការទូទាត់របស់លោកអ្នក សំរាប់ពេលក្រោយទៀតដែលលោកអ្នកអញ្ជើញទៅហាងលក់ទំនិញ ។

គេមិនអាចគិតថ្លៃប្រើប័ណ្ណជំនួយសំរាប់ទិញម្ហូបចំណីរបស់លោកអ្នកឡើយ ។

តើត្រូវឆែកមើលចំនួនប្រាក់នៅសល់ក្រោយពីការទូទាត់នៅក្នុងប័ណ្ណ EBT របស់លោកអ្នកក្នុងបែបណា?

ចំនួនប្រាក់នៅសល់ថ្មីក្រោយពីការទូទាត់របស់លោកអ្នក គឺមានបោះពុម្ពប្រាប់នៅពីលើបង្កាន់ដៃចុងក្រោយរបស់លោកអ្នក ។ សូមរក្សារទុកបង្កាន់ដៃរបស់លោកអ្នកជាគិច្ច ។ ប្រសិនបើលោកអ្នកបាត់បង្កាន់ដៃចុងក្រោយរបស់លោកអ្នក នោះលោកអ្នកអាចទូរស័ព្ទទៅផ្នែកបំរើអតិថិជន ឬស្នើសុំហាងលក់ទំនិញនោះដើម្បីអោយលោកអ្នកអាចឆែកមើលចំនួនប្រាក់នៅសល់ក្រោយពីការទូទាត់របស់លោកអ្នក នៅតាមម៉ាស៊ីន POS ។

ប្រសិនបើលោកអ្នកបានបាត់ប័ណ្ណ ឬត្រូវគេលួចយកប័ណ្ណរបស់លោកអ្នក សូមទូរស័ព្ទទៅផ្នែកបំរើអតិថិជនភ្លាម តាមលេខឥតគិតថ្លៃ 1-877-328-9677 ។ គេនឹងជំរាបប្រាប់លោកអ្នកអំពីរបៀបទទួលយកប័ណ្ណថ្មីមួយទៀត ។ ប្រសិនបើលោកអ្នកមិនបានរាយការណ៍ប្រាប់អំពីការបាត់ប័ណ្ណ ឬត្រូវគេលួចយកប័ណ្ណរបស់លោកអ្នកទេ ទរណា ផ្សេងទៀតអាចប្រើប័ណ្ណរបស់លោកអ្នក ហើយដកចាយប្រាក់ជំនួយរបស់លោកអ្នកទាំងអស់ ។ លោកអ្នកមិនអាចទទួលយកប្រាក់ដើម្បីជំនួសប្រាក់ជំនួយទាំងនេះបានទេ ។

សូមទូរស័ព្ទទៅផ្នែកបំរើអតិថិជន តាមលេខឥតគិតថ្លៃ ប្រសិនបើ:

- លោកអ្នកបាត់ប័ណ្ណ ឬត្រូវគេលួចយកប័ណ្ណរបស់លោកអ្នក ។
- ប័ណ្ណរបស់លោកអ្នកខូចដោយប្រើការពុំកើត ។
- លោកអ្នកមានបំណងចង់ប្តូរលេខសម្ងាត់ PIN របស់លោកអ្នក ដ្បិតតីលោកអ្នកភ្លេចវាឬមានឧទរណាផ្សេង ទៀតស្គាល់លេខសម្ងាត់ PIN របស់លោកអ្នក ។
  ភ្នាក់ងារជំនួយសាធារណៈរបស់លោកអ្នក ក៍អាចជួយលោកអ្នកប្តូរលេខសម្ងាត់ PIN របស់លោកអ្នកបានដែរ ។
- លោកអ្នកមានបំណងចង់ដឹងអំពីចំនួនប្រាក់ជំនួយរបស់លោកអ្នកដែលនៅសល់ក្រោយពីការទូទាត់ ។
- លោកអ្នកត្រូវបានគេគិតថ្លៃទិញ ក៍ប៉ុន្តែលោកអ្នកមិនបានទទួលទំនិញ ឬគេគិតប្រាក់លោកអ្នកលើសពីចំនួន ដែលលោកអ្នកបានទិញ ។
- លោកអ្នកមានសំណួរ ឬបញ្ហាផ្សេងទៀត ។

ធ្វើការ២៤ម៉ោងក្នុង១ថ្ងៃ / ៧ថ្ងៃក្នុង១អាទិត្យ

1-877-328-9677

TTY: 1-800-735-2929

យោងទៅតាមតារាងនៅក្នុងកូនស្បៃរៅចណ្តុះបណ្តាល EBT របស់លោកអ្នក ហើយដាក់បញ្ចូលថ្ងៃដែលប្រាក់ជំនួយនឹងត្រូវបានគេដាក់បញ្ចូលទៅក្នុងគណនីរបស់លោកអ្នក:

(ថ្ងៃទី១ ទៅទល់នឹងថ្ងៃទី១០ នៃខែនោះ)

State of California
Arnold Schwarzenegger, Governor
Health and Human Services Agency
Kimberly Belshé, Secretary
Department of Social Services

USDA is an equal opportunity provider and employer.

PUB 390 (Cambodian) (2/06)